អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សេចក្តីថ្លែងការណ៍រួមដោយចៅក្រមជាតិនិងអន្តរជាតិ
ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០០៧

# សម័យប្រជុំពេញអង្គអនុម័តជាឯកច្ឆ័ន្ទលើវិធានផ្ទៃក្នុង

កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ កិច្ចប្រជុំពេញអង្គនៃចៅក្រមជាតិនិងអន្តរជាតិបានអនុម័តជាឯកច្ឆ័ន្ទលើវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយបានធ្វើការបញ្ចប់កិច្ចប្រជុំរយះពេលពីសប្តាហ៍នៅក្នុងទីក្រុងភ្នំពេញ។

ដំណើរការនៃការពង្រាងវិធានផ្ទៃក្នុងនេះគឺជាការងារមួយដ៏លំបាក។ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាជាស្ថាប័នតុលាការដែលមានលក្ខណៈពិសេសដោយឡែកនៅក្នុងឆាកយុត្តិធម៌អន្តរជាតិ។ នេះជាលើកទី១ហើយដែលតុលាការកូនកាត់មួយនេះបានរួមបញ្ចូលការងាររបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយយកច្បាប់ជាតិដែលកំពុងអនុវត្តជាមូលដ្ឋានគ្រឹះ។ យើងមិនមានករណីយុត្តិសាស្ត្រឡើយនៅពេលដែលយើងធ្វើការច្របាច់បញ្ចូលគ្នារវាងច្បាប់ជាតិនិងនីតិវិធីនិងលក្ខណៈពិសេសទាំងឡាយព្រមទាំងរចនាសម្ព័ន្ធរបស់តុលាការនេះ ដោយព្យាយាមធ្វើយ៉ាងណាធានាអោយបានបទដ្ឋានអន្តរជាតិ។

ក្នុងរយះពេល១១ខែក្រោយពីការពិភាក្សាកន្លងមកនេះ ចៅក្រមមកពីប្រទេសដទៃៗដែលអនុវត្តប្រព័ន្ធច្បាប់ខុសៗគ្នា រួមទាំងចៅក្រមមកពីប្រទេសដែលអនុវត្តប្រព័ន្ធច្បាប់អង់គ្លូសាក់សុងផងនោះ បានស្វែងរកដំណោះស្រាយដែលអាចទទួលយកបាននិងមានការឃោគយល់គ្នា ដើម្បីធានាអោយមានការជំនុំជម្រះដោយមានភាពយុត្តិធម៌។

យើងខ្ញុំបានដោះស្រាយរួចរាល់លើបញ្ហានានាដែលយើងខ្ញុំបានចង្អុលបង្ហាញពីតម្រូវការពិភាក្សាបន្ថែមកាលពីខែវិច្ឆិកាកន្លងផុតទៅនេះ។ បញ្ហាដែលមានលក្ខណៈស្មុគស្មាញជាងគេនោះគឺធ្វើយ៉ាងណាដើម្បីធានាអោយបាននូវសិទ្ធិនិងការចូលរួមរបស់ជនរងគ្រោះ។ ចំនុចនេះមិនមានចែងអោយបាន

ច្បាស់លាស់នៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះនិងកិច្ចព្រមព្រៀងទេ តែវាជាសមាសធាតុមួយដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់កម្ពុជារបស់យើង។ យើងខ្ញុំយល់ឃើញថាជនរងគ្រោះអាចមានសិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក៏ប៉ុន្តែ ដោយសារតែពិចារណាលើលក្ខណៈពិសេសរបស់អង្គជំនុំជម្រះរបស់យើងនោះ យើងខ្ញុំបានធ្វើការសម្រេចថានឹងបើកអោយមានសំណងជាសមូហភាព តែមិនមែនក្នុងលក្ខណៈជាហិរញ្ញវត្ថុនោះឡើយ។

យើងខ្ញុំមានសេចក្តីរីករាយណាស់ដោយបានធ្វើសេចក្តីសម្រេចចុងក្រោយលើវិធានទាំងនេះក្នុងពេលមួយដែលសមស្រប បើពិនិត្យមើលលើភាពស្មុគស្មាញទាំងឡាយនិងបន្ទាប់ពីមានការពិភាក្សាពិគ្រោះយោបល់និងបំពេញការងារដ៏ច្រើននេះ។ នេះគឺជាដំណើរការមួយដ៏មានតំលៃហើយមានសារៈសំខាន់ណាស់ក្នុងការចំណាយពេលរៀបចំចងក្រងនូវពង្រាងនេះឡើង។ ក្នុងរយៈពេលមិនដល់មួយឆ្នាំផង អង្គជំនុំជម្រះមិនត្រឹមតែបានអនុម័តលើវិធានផ្ទៃក្នុងរបស់ខ្លួនទេ ថែមទាំងបានចាប់ផ្តើមការរៀបចំផ្សេងៗទៀតដើម្បីអោយតុលាការនេះដំណើរការបានពេញលេញ។

ឥឡូវនេះ វិធានផ្ទៃក្នុងត្រូវបានអនុម័តរួចរាល់ហើយ ហើយយើងអាចដំណើរការទៅមុខបាន។ យើងខ្ញុំយល់ឃើញថាសហព្រះរាជអាជ្ញានឹងបញ្ជូនដីកាសន្និដ្ឋានអោយស៊ើបសួរលើកដំបូងរបស់ខ្លួនក្នុងពេលដ៏ខ្លីខាងមុខនេះ។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេតអាចចាប់ផ្តើមបំពេញកិច្ចស៊ើបសួររបស់ខ្លួន។ ហើយនៅក្នុងថ្ងៃនេះផងដែរ អង្គជំនុំជម្រះវិសាមញ្ញនឹងបើកការជំនុំជម្រះលើកទីមួយរបស់ខ្លួននៅពេលចៅក្រមនៃអង្គបុរេជំនុំជម្រះបើកសាវនាការដើម្បីអនុញ្ញាត្តិអោយអ្នកស៊ើបអង្កេតធ្វើសច្ចាប្រណិធានចូលកាន់ដំណែង។

ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញទាំងអស់ដឹងយ៉ាងច្បាស់ថា ប្រជាជនកម្ពុជាទន្ទឹងរងចាំការដំណើរការរបស់សាលាក្តីនេះអស់រយៈពេលយ៉ាងយូរមកហើយ។ យើងខ្ញុំទាំងអស់គ្នាធ្វើការផ្តេជ្ញាចិត្តធ្វើការជំនុំជម្រះអោយបានរួសរាន់ទាន់ពេល ដោយធានាអោយបាននូវបទដ្ឋានយុត្តិធម៌ដ៏ខ្ពស់បំផុត។ វិធានទាំងនេះអាចផ្តល់ឱកាសអោយយើងខ្ញុំអាចដំណើរការកាត់ក្តីដ៏មានភាពយុត្តិធម៌និងតម្លាភាពនៅចំពោះមុខសាលាក្តីឯករាជ្យនិងអព្យាក្រឹត្យមួយនេះ៕